# យោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិវប្បធម៌ សង្គម និងសេដ្ឋកិច្ច ទី១ ស្តីពី របាយការណ៍របស់រដ្ឋជាភាគី

## (អត្ថបទបកប្រែ)

១. កាតព្វកិច្ចធ្វើរបាយការណ៍ ដែលមានកំណត់ក្នុងផ្នែកទី៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រូវបានបង្កើតឡើង ដើម្បីជួយដល់រដ្ឋភាគីទាំងអស់ ក្នុងការបំពេញកាតព្វកិច្ច ដែលកំណត់ដោយកតិកាសញ្ញា ។ លើសពីនេះទៅទៀត កាតព្វកិច្ចនេះ ក៏ជាមូលដ្ឋាន ដែលក្រុមប្រឹក្សាជាមួយជំនួយពីគណៈកម្មាធិការ អាចបំពេញនូវការទទួលខុសត្រូវ ក្នុងការឃ្លាំមើលការអនុវត្តតាមកាតព្វកិច្ចរបស់ពួកគេ ព្រមទាំងសម្រួលដល់ការដឹងជ្រួតជ្រាប (realization) នូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ស្របទៅតាមបញ្ញត្តិនៃកតិកាសញ្ញានេះ ។ គណៈកម្មាធិការ យល់ឃើញថា វាការជាខុសឆ្គង ដែលគេសន្មត់ថា ការធ្វើរបាយការណ៍គឺគ្រាន់តែជាបញ្ហានីតិវិធី ដែលត្រូវបានបង្កើតឡើង ដើម្បីតែបំពេញតាមកាតព្វកិច្ចផ្លូវការរបស់រដ្ឋភាគីនីមួយៗ ដើម្បីរាយការណ៍ជូន ស្ថាប័នឃ្លាំមើល។ ផ្ទុយទៅវិញ បើយោងទៅតាមអត្ថបទ និងស្មារតីរបស់កតិកាសញ្ញានេះ ដំណើរការនៃការរៀបចំ និងការដាក់របាយការណ៍ ដោយរដ្ឋភាគី ជាកត្តាមួយដែលនាំឱ្យសម្រេចបាននូវគោលដៅផ្សេងៗជាច្រើន ។

២. *គោលដៅទី១* មានទំនាក់ទំនងជាពិសេស ជាមួយនឹងរបាយការណ៍ដំបូង ទាមទារឲ្យដាក់ជូន ក្នុងអំឡុងពេល២ឆ្នាំ ចាប់ពីថ្ងៃដែលកតិកាសញ្ញាបានចូលជាធរមាន សម្រាប់រដ្ឋភាគីនោះ ដើម្បីធានាថា ការត្រួតពិនិត្យស៊ីជម្រៅមួយត្រូវបានធ្វើពាក់ព័ន្ធនឹងជាមួយនឹងច្បាប់ វិធាន និងនីតិវិធីរដ្ឋបាល ក្នុងការខិតខំ

ប្រឹងប្រែង ដើម្បីធានា នូវអនុលោមភាព ពេលលេញនឹងកតិកាសញ្ញានេះ តាមតែអាចធ្វើបាន។ ជាឧទាហរណ៍ ការពិនិត្យនេះ អាចធ្វើឡើងរួមគ្នាជាមួយក្រសួងពាក់ព័ន្ធ ឬស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដែលមានតួនាទីក្នុងការបង្កើត និងអនុវត្តគោលនយោបាយថ្នាក់ជាតិ ក្នុងវិស័យផ្សេងៗ ដែលស្ថិតនៅក្នុងវិសាលភាពនៃកតិកាសញ្ញានេះ ។

៣. *គោលដៅទី២* ដើម្បីធានាថា រដ្ឋភាគី បានឃ្លាំមើលស្ថានភាពជាក់ស្តែង ពាក់ព័ន្ធនឹងសិទ្ធិនីមួយៗ ជាទៀងទាត់ ហើយរដ្ឋភាគីបានដឹងពីវិសាលភាពដែល សិទ្ធិទាំងឡាយត្រូវបានប្រាស្រ័យ ឬក៏មិនដោយបុគ្គលទាំងឡាយ នៅក្នុងដែនដី ឬក្រោមយុត្តាធិការរបស់ខ្លួន ។ យោងតាមបទពិសោធន៍ របស់គណៈកម្មាធិការរហូតមកដល់បច្ចុប្បន្ន វាមានភាពច្បាស់លាស់ថា ការបំពេញតាមគោលដៅនេះ មិនអាចសម្រេចបានដោយគ្រាន់តែរៀបចំស្ថិតិជាតិសរុប ឬការប៉ាន់ស្មាននោះទេ ប៉ុន្តែត្រូវការផងដែរ នូវការយកចិត្តទុកដាក់ជាពិសេស ទៅលើតំបន់ដែលមានស្ថានភាពអាក្រក់បំផុត ឬចំពោះក្រុមមួយចំនួន ដែលមានវិបត្តិ និង ក្រុមមនុស្សជាក់លាក់ ដែលទំនងជាងាយរងគ្រោះ ។ ហេតុនេះហើយ ជំហានចំបងទីមួយឆ្ពោះទៅកាន់ការលើកកម្ពស់ការយល់ដឹងអំពី សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គឺការវិភាគ និងចំណេះដឹងអំពីស្ថានភាពដែលកំពុងកើតឡើង ។ គណៈកម្មាធិការ យល់ឃើញថា ដំណើរការនៃការតាមដាន (monitoring) និងប្រមូលព័ត៌មាននេះចំណាយពេលវេលា និងថវិកាច្រើន ដែលត្រូវឱ្យមានជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងមាត្រា២ កថាខណ្ឌទី១ មាត្រា ២២ និងមាត្រា ២៣ នៃកតិកាសញ្ញា ដើម្បីឱ្យរដ្ឋភាគី អាចបំពេញតាមកាតព្វកិច្ច

នេះបាន ។ ប្រសិនបើដូចនេះមែន ហើយរដ្ឋភាគី យល់ថា ខ្លួនមិនមានសមត្ថភាព អនុវត្តដំណើរការត្រួតពិនិត្យ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងចំណោមផ្នែកដទៃទៀត ដែលត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់គោលដៅឯកភាព នៃគោលនយោបាយសាធារណៈ និង មិនអាចខ្វះបានសម្រាប់ប្រតិបត្តិកតិកាសញ្ញានេះ ឱ្យមានប្រសិទ្ធភាព ។ រដ្ឋអាចកត់ត្រានូវចំណុចនេះ នៅក្នុងរបាយការណ៍របស់ខ្លួន ដាក់ជូនគណៈកម្មាធិការ ព្រមទាំងបង្ហាញអំពីប្រភេទ និង វិសាលភាពនៃជំនួយបរទេស ដែលខ្លួនត្រូវការផងដែរ ។

៤. ខណៈដែលដំណើរការតាមដាន ត្រូវបានបង្កើតឡើង ដើម្បីផ្តល់នូវទិដ្ឋភាពលម្អិតអំពីស្ថានភាពដែលបានកើតឡើង តម្លៃចម្បង (principal value) នៃទិដ្ឋភាពនោះគឺផ្តល់នូវមូលដ្ឋានសម្រាប់ការតាក់តែង គោលនយោបាយ ដែលមានភាពច្បាស់លាស់ និងផ្តោតដោយប្រុងប្រយ័ត្នខ្ពស់ រួមទាំង ការកំណត់អាទិភាព ដែលបង្ហាញឱ្យឃើញនូវបទប្បញ្ញត្តិនៃកតិកាសញ្ញា។ ហេតុនេះ *គោលដៅទី៣* នៃដំណើរការធ្វើរបាយការណ៍ គឺដើម្បីជួយរដ្ឋាភិបាល ក្នុងការបង្ហាញថា ការបង្កើតគោលនយោបាយដែលមានគោលការណ៍ត្រឹមត្រូវនេះ ត្រូវបានប្រកាន់យក។ ខណៈដែលកតិកាសញ្ញា បានចែងកាតព្វកិច្ចនេះយ៉ាងច្បាស់ នៅក្នុងមាត្រា ១៤ ថា “ការអប់រំមូលដ្ឋាន (Compulsory Education) នៅបឋមសិក្សា មិនត្រូវគិតប្រាក់ឡើយ” មិនទាន់ត្រូវបានធានាគ្រប់គ្នា កាតព្វកិច្ចស្រដៀងនេះ “ការដាក់ចេញ និងអនុម័តគម្រោងសកម្មភាពលម្អិត សម្រាប់ការប្រតិបត្តិប្រកបដោយវឌ្ឍនភាព” នៃសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញា ត្រូវបានចែងយ៉ាង

ច្បាស់ នៅក្នុងមាត្រា២ កថាខណ្ឌទី១ ដែលមានខ្លឹមសារ “ដើម្បីអនុវត្តជំហាន.... ដោយប្រើគ្រប់មធ្យោបាយសមស្រប...”។

៥. *គោលដៅទី៤* នៃដំណើរការធ្វើរបាយការណ៍ ដើម្បីសម្រួលនូវការពិនិត្យជាសាធារណៈនូវ គោលនយោបាយរបស់រដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការចូលរួមក្នុងកិច្ចការសង្គមនានា ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្នុងការបង្កើតការប្រតិបត្តិ និងការត្រួតពិនិត្យគោលនយោបាយពាក់ព័ន្ធ ។ នៅពេលធ្វើការពិនិត្យរបាយការណ៍ ដែលរដ្ឋភាគី បានដាក់ជូន មកដល់ពេលនេះ គណៈកម្មាធិការបានស្វាគមន៍ការណ៍ ដែលរដ្ឋភាគីមួយចំនួនមានប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយផ្សេងៗគ្នា បានលើកទឹកចិត្តនូវធាតុចូលពីក្រុមមិនមែនរដ្ឋាភិបាល (non-governmental Groups) ទៅក្នុងការរៀបចំរបាយការណ៍របស់ខ្លួន ។ រដ្ឋផ្សេងទៀត បានធានានូវការផ្សព្វផ្សាយរបាយការណ៍របស់ខ្លួនទូលំទូលាយ ក្នុងគោលបំណងទទួលបានមតិយោបល់ ពីសាធារណៈជនទូទៅ ។ តាមមធ្យោបាយនេះ ការរៀចំរបាយការណ៍ និងការពិចារណារបាយការណ៍ នៅថ្នាក់ជាតិ អាចទទួលបានតម្លៃខ្ពស់ ដូចជាការសន្ទនាគ្នា ដែលធ្វើឡើងរវាងគណៈកម្មាធិការនិងតំណាងរដ្ឋនៅថ្នាក់អន្តរជាតិអញ្ចឹងដែរ ។

៦. *គោលដៅទី៥* ដើម្បីផ្តល់នូវមូលដ្ឋាន សម្រាប់ការវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដោយរដ្ឋភាគី ក៏ដូចជាដោយគណៈកម្មាធិការផងដែរ នូវការយល់ដឹងនូវកាតព្វកិច្ច ដែលបានកំណត់ដោយកតិកាសញ្ញានេះ ។ សម្រាប់គោលបំណងនេះ វាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះរដ្ឋជាភាគី ក្នុងការកំណត់គោល

ដៅ ដែលការប្រតិបត្តិការងារក្នុងវិស័យជាក់លាក់ ត្រូវបានវាស់វែងធៀបជាមួយ។ ឧទាហរណ៏ ជាទូទៅ គេឯកភាពថា វាជាការសំខាន់ ក្នុងការកំណត់គោលដៅជាក់លាក់ក្នុងការកាត់បន្ថយការស្លាប់របស់ទារក ការបង្កើនវ៉ាក់សាំងសម្រាប់កុមារ ការផ្តល់នូវបរិមាណកាឡូរីសម្រាប់មនុស្សម្នាក់ៗ ការកំណត់ចំនួនមនុស្សដែលត្រូវទទួលសេវាថែទាំសុខភាពសម្រាប់គ្រូពេទ្យម្នាក់ៗជាដើម។ នៅក្នុងវិស័យមួយចំនួននេះ មូលដ្ឋានជាសកល ត្រូវបានប្រើប្រាស់ដោយមានកម្រិត ខណៈដែលមូលដ្ឋានដទៃទៀត ឬរបស់ជាតិ អាចផ្តល់នូវសូចនាករមានតម្លៃជាខ្លាំងនៃភាពប្រសើរឡើង។

៧. ពាក់ព័ន្ធនឹងបញ្ហានេះ គណៈកម្មាធិការសូមកត់សម្គាល់ថា កតិកាសញ្ញានេះផ្តល់នូវសារៈសំខាន់ជាច្រើន លើគោលគំនិត “ការអនុវត្តប្រកបដោយវឌ្ឍនភាព” ចំពោះសិទ្ធិពាក់ព័ន្ធ។ ហេតុនេះហើយ គណៈកម្មាធិការជម្រុញ រដ្ឋភាគី ឱ្យដាក់ក្នុងរបាយការណ៏តាមកាលកំណត់របស់ខ្លួន នូវព័ត៌មានដែលបង្ហាញអំពីវឌ្ឍនភាពនានា ក្នុងរយៈពេលកន្លងមក ពាក់ព័ន្ធទៅនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃសិទ្ធិពាក់ព័ន្ធទាំងឡាយ ។ ដូចគ្នានេះដែរ ទិន្នន័យជាគុណភាព ឬជាបរិមាណ គឺជាតម្រូវការចាំបាច់ សម្រាប់ការវាយតម្លៃនូវស្ថានភាព។

៨. *គោលដៅទី៦* ដើម្បីជួយឱ្យរដ្ឋភាគី អភិវឌ្ឍនូវការយល់ដឹងរបស់ខ្លួនលើបញ្ហា និងចំណុចខ្វះខាតដែលជួបប្រទះ សម្រាប់នាំឲ្យមានវឌ្ឍនភាពពេញលេញនូវ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ ហេតុផលនេះ វាមានសារៈសំខាន់ដែលរដ្ឋភាគី ត្រូវធ្វើរបាយការណ៏លម្អិតអំពី “កត្តា និងឧបសគ្គ” រារាំងការអនុវ

ត្ត។ ដំណើរការនៃការកំណត់ និងទទួលស្គាល់រាល់ឧបសគ្គពាក់ព័ន្ធ នឹងនាំមកនូវក្របខណ្ឌមួយដែលអាចឱ្យរដ្ឋបង្កើតគោលនយោបាយសមស្រប ។

៩. *គោលដៅទី៧* ដើម្បីជួយឱ្យគណៈកម្មាធិការ និងរដ្ឋភាគីទាំងអស់ ក្នុងការសម្រួលនូវការប្តូរព័ត៌មានគ្នារវាងរដ្ឋ និងរដ្ឋ ក៏ដូចជាដើម្បីអភិវឌ្ឍនូវការយល់ដឹងកាន់តែប្រសើរចំពោះបញ្ហាទូទៅ ដែលរដ្ឋភាគីបានប្រឈម និង វាយតម្លៃពេញលេញនូវវិធានការ ដែលអាចប្រកាន់យក ដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវសិទ្ធិនីមួយៗ ដែលមានចែងក្នុងកតិកាសញ្ញានេះ ។ ផ្នែកនៃដំណើរការនេះ ក៏អាចជួយឱ្យគណៈកម្មាធិការ កំណត់អំពីមធ្យោបាយសមស្រប ដែលសហគមន៍អន្តរជាតិ អាចជួយដល់រដ្ឋ ស្របតាមមាត្រា ២២ និង ២៣ នៃកតិកាសញ្ញានេះផងដែរ ។ ដើម្បីបញ្ជាក់នូវសារៈសំខាន់ ដែលគណៈកម្មាធិការផ្តោតការយកចិត្តទុកដាក់ មតិយោបល់ទូទៅដោយឡែក ស្តីពីមាត្រាទាំងនេះ នឹងត្រូវពិភាក្សា ក្នុងកិច្ចប្រជុំលើកទី ៤របស់ខ្លួន។

Compilation of General Comments adopted by Human Rights Treaty Body,Vol. I, HRI/GEN/1/Rev. 9 (Vol.I), 27 May 2008.

http://www.measboralaws.com/detail/1099